**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៤២១៣ ព.ណ.ការយ

ថ្ងៃចន្ទ ១រោច ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៩

**ជម្រាបមក**

**លោក/លោកស្រីប្រធាន ក្រុមហ៊ុន យូនីលីវើ (ខេមបូឌា) លីមីធីត**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ លើផលិតផលម្សៅសាប៊ូសម្រាប់បោកគក់ម៉ាក "VISO" និង "BREEZE" សាប៊ូសម្រាប់ព្យាបាលសក់ និងកក់សក់ម៉ាក "CLEAR" និង "DOVE" សាប៊ូសម្រាប់ដុសខ្លួនម៉ាក "LUX" ផលិតផលសម្រាប់ការពារ និងសម្អាតធ្មេញម៉ាក "CLOSE UP" និង "SIGNAL" ផលិតផលសម្រាប់ការពារផ្ទៃមុខ និងសម្អាតផ្ទៃមុខម៉ាក "VASELINE" ផលិតផលសម្រាប់លាបការពារស្បែកម៉ាក "CITRA" ផលិតផលសម្រាប់បន្ថែមក្លិនក្រអូបដល់សំលៀកបំពាក់សម្រាប់ការបោកគក់ម៉ាក "COMFORT" សាប៊ូសម្រាប់លាងចានម៉ាក "SUNLIGHT" ផលិតផលសម្រាប់លាបមុខ និងការពារកម្តៅថ្ងៃម៉ាក "FAIR & LOVELY" និង ការ៉េមម៉ាក "WALL'S" ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **យូនីលីវើ (ខេមបូឌា) លីមីធីត**។

**យោង:**- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **យូនីលីវើ (ខេមបូឌា) លីមីធីត** ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Unilever N.V. ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៧៩៥៦/៩៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/២០៤៣/៩២ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/២០៦៤១/០៤ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/២០៣៧/៩២ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/២០៣៦/៩២ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៩៦៨៧/៩៧ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៦០៤៥៥/១៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១២២២៥/៩៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៨១៤៧/៩៦ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៥១៧/៩២ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/២០២៤/៩២ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៦៨០៥៨/១៨ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១០៨៧៧/៩៨ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលម្សៅសាប៊ូសម្រាប់បោកគក់ សាប៊ូសម្រាប់ព្យាបាលសក់ និងកក់សក់ សាប៊ូសម្រាប់ដុសខ្លួន ផលិតផលសម្រាប់ការពារ និងសម្អាតធ្មេញ ផលិតផលសម្រាប់ការពារផ្ទៃមុខ និងសម្អាតផ្ទៃមុខ ផលិតផលសម្រាប់លាបការពារស្បែក ផលិតផលសម្រាប់បន្ថែមក្លិនក្រអូបដល់សំលៀកបំពាក់ និងសម្រាប់ការបោកគក់ សាប៊ូសម្រាប់លាងចាន ផលិតផលសម្រាប់លាបមុខ និងការពារកម្តៅថ្ងៃ និងការ៉េមពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **យូនីលីវើ (ខេមបូឌា) លីមីធីត** ដែលទទួលបានពីក្រុមហ៊ុន Unilever N.V. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

លិខិតកត់ត្រា និងតម្កល់សិទ្ធិផ្ដាច់មុខនេះមានសុពលភាពត្រឹមថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Unilever N.V. ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខនេះ អ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

អ៊ុក-ប្រុជា

ចម្លងជូន:

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ - កាលប្បវត្តិ